# អដ្ឋង្គិកមគ្គ

អដ្ឋង្គិកមគ្គជាថ្នាំស័ក្តិសិទ្ធិ　　ដោយថ្វីគំនិតព្រះតថាគត
ឫសទុក្ខរំលើងឲ្យយើងរួចផុត　　ជួបសុខវិសុទ្ធវិសេសប្រាកដ។
១-សម្មាទិដ្ឋិយល់ច្បាស់ពីទុក្ខ　　យល់ហេតុគ្រប់មុខយល់ទុក្ខរលត់
យល់ច្បាស់មាគ៌ាជាថ្នាំកំណត់　　ប្រាំបីគ្រាប់គត់រំលត់ទុក្ខពិត។
២-សម្មាសង្កប្បោការគិតត្រូវ　　លាចាកកាមទៅជាបព្វជិត
មិនចងអាឃាតដល់ញាតិនិងមិត្ត　　មិនផ្តាច់ជីវិតសត្វជិតឆ្ងាយខ្លួន។
៣-សម្មាវាចាថាពោលពាក្យត្រូវ　　គោរពតាមផ្លូវវិថីកម្មបួន
កុំពោលកុហកអាក្រក់ខុសក្បួន　　ញុះញង់អង្រួនរោយរាយវាចា។
៤-សម្មាកម្មន្តោធ្វើការងារត្រូវ　　សមាទានតាមផ្លូវសីលបីសិក្ខា
វៀរយកទ្រព្យគេមេថុនកាមា　　និងវៀរកិច្ចការដែលជាឃាតករ។
៥-សម្មាអាជីវោចិញ្ចឹមជីវិត　　ដោយត្រឹមត្រូវពិតតាមគន្លងធម៌
កុំធ្វើជំនួញ សាច់ សត្វនិករ　　ថ្នាំពុលញៀនញ៉េរ អាវុធ សុរា។
៦-សម្មាវាយាមោព្យាយាមត្រូវ　　កំចាត់បាបផ្លូវកុំឲ្យខ្លាំងក្លា
ព្យាយាមធ្វើល្អហើយខំរក្សា　　បង្កើនកុសលាថ្លៃថ្លាពេកពាន់។
៧-សម្មាសតិភ្ញាក់រឭកត្រូវ　　ដឹងខ្លួនតទៅជារៀងនិរន្តរ៍
យល់ច្បាស់ខន្ធ ៥ ជាទុក្ខដ៏ធ្ងន់　　និងយល់រូបមន្តនៃព្រះត្រៃលក្ខណ៍។
៨-សម្មាសមាធិតាំងចិត្តត្រូវល្អ　　បំបាត់នូវធម៌នីវរណៈ
ទាំងប្រាំប្រការជាឧបស័គ្គ　　គឺធម៌រាំងស្ទាក់ចិត្តជាកុសល។
មួយគេហៅថាកាមច្ឆន្ទៈ　　ប្រាថ្នារួមរាក់កាមកើតកង្វល់
ពីរព្យាបាទៈអ្នកជាបុគ្គល　　ឯទៃគ្មានសល់វិនាសខ្លួនធ្លាក់។
បីងោកងុយងក់ទ្រមក់ច្រអូស　　រួញរាចិត្តនោះគឺថីនមិទ្ធៈ
ទីបួនឧទ្ធច្ចៈកុក្កុច្ចៈ　　រាយមាយមោឃៈនិងក្តៅក្រហាយ។
ទីប្រាំហៅថាវិចិកិច្ឆា　　មិនអស់ចិន្តាសន្ទិះសង្ស័យ
យើងត្រូវកំចាត់ធម៌៥កុំស្តាយ　　នោះទើបប្រែក្លាយសប្បាយចិត្តស្ងប់៕

ធ្វើនៅសោរិ៍ស ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ ត្រូវនិងថ្ងៃ ២ ៦ ១១ ព.ស.២៥៥៦

នន្ទ នាថ ក្មេងវត្តព្រៃក្រឡា